**ព្រះរាជាណាចក្រកម្ពុជា**
ជាតិ សាសនា ព្រះមហាក្សត្រ

**ធនាគារជាតិ នៃ កម្ពុជា**

លេខ ធ៨ ០១៤ ២៣១ ប្រ.ក

# ប្រកាស
## ស្តីពី
## រូបសញ្ញា សញ្ញាស័ក្តិ និងឯកសណ្ឋានមន្ត្រី ក្របខ័ណ្ឌមន្ត្រីជាន់ខ្ពស់ និងក្របខ័ណ្ឌមន្ត្រីក្រមការ ធនាគារជាតិនៃកម្ពុជា

*******

## ទេសាភិបាលធនាគារជាតិនៃកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៤១២/៣៣៧ ចុះថ្ងៃទី១៧ ខែមេសា ឆ្នាំ២០១២ ស្តីពីការតែងតាំង ឯកឧត្តម ជា ចាន់តូ ជាអគ្គទេសាភិបាលធនាគារជាតិនៃកម្ពុជា ជាថ្មី មានឋានៈស្មើទេសរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/២៧ ចុះថ្ងៃទី២៦ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃធនាគារជាតិនៃកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២០៦/០៣៦ ចុះថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០០៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មមាត្រា ១៤ និងមាត្រា ៥៧ នៃច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃធនាគារជាតិនៃកម្ពុជា
- បានឃើញប្រកាសលេខ ធ៨.៩៩.១២៤ ប្រក ចុះថ្ងៃទី១៥ ខែវិច្ឆិកា ឆ្នាំ១៩៩៩ ស្តីពីលក្ខន្តិកៈដោយឡែកនៃក្របខ័ណ្ឌមន្ត្រីជាន់ខ្ពស់ធនាគារជាតិនៃកម្ពុជា
- បានឃើញប្រកាសលេខ ធ៨.៩៩.១២៣ ប្រក ចុះថ្ងៃទី១៥ ខែវិច្ឆិកា ឆ្នាំ១៩៩៩ ស្តីពីលក្ខន្តិកៈដោយឡែកនៃក្របខ័ណ្ឌមន្ត្រីក្រមការធនាគារជាតិនៃកម្ពុជា
- បានឃើញប្រកាសលេខ ធ៨.៩៨.៣៨៥ ប្រក ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៨ ស្តីពីរចនាសម្ព័ន្ធរបស់ធនាគារជាតិនៃកម្ពុជា និងមុខងារ-ភារកិច្ចរបស់បណ្តាអង្គភាពក្រោមឱវាទ
- បានឃើញប្រកាសលេខ ធ៨.០១០.១៩៤ ប្រក ចុះថ្ងៃទី២៦ ខែវិច្ឆិកា ឆ្នាំ២០១០ ស្តីពីការកែសម្រួលប្រការ៣ ប្រការ៤ ប្រការ៥ ប្រការ១២ និងប្រការ១៣ នៃប្រកាសស្តីពីរចនាសម្ព័ន្ធរបស់ធនាគារជាតិនៃកម្ពុជា និងមុខងារ-ភារកិច្ចរបស់បណ្តាអង្គភាពក្រោមឱវាទ
- យោងស្មារតីអង្គប្រជុំថ្នាក់ដឹកនាំធនាគារជាតិនៃកម្ពុជា នៅថ្ងៃទី៨ ខែកញ្ញា ឆ្នាំ២០១៤



ប្រអប់សំបុត្រលេខ ២៥, ផ្លូវលេខ ២២-២៤ មហាវិថី ព្រះនរោត្តម រាជធានីភ្នំពេញ, ទូរស័ព្ទ : (៨៥៥-២៣) ៧២២ ៥៦៣, ទូរស័ព្ទ . ទូរសារ : (៨៥៥-២៣) ៤២៦ ១១៧

## សម្រេច

## ជំពូកទី ១
## បទប្បញ្ញត្តិទូទៅ

**ប្រការ ១.-**

ប្រកាសនេះមានគោលបំណងរៀបចំរូបសញ្ញាធនាគារជាតិនៃកម្ពុជា សញ្ញាស័ក្តិ និងឯកសណ្ឋានសម្រាប់សម្គាល់មន្ត្រីក្របខ័ណ្ឌមន្ត្រីជាន់ខ្ពស់ និងក្របខ័ណ្ឌមន្ត្រីក្រមការធនាគារជាតិនៃកម្ពុជា។

សញ្ញាស័ក្តិ និងឯកសណ្ឋានសម្រាប់សម្គាល់ទេសាភិបាល និងទេសាភិបាលរងធនាគារជាតិនៃកម្ពុជា មានកំណត់នៅក្នុងព្រះរាជក្រឹត្យដោយឡែក។

**ប្រការ ២.-**

ប្រកាសនេះមានគោលដៅលើកកម្ពស់សេចក្តីថ្លៃថ្នូរនិងកិត្តិយសរបស់មន្ត្រីធនាគារជាតិនៃកម្ពុជានៅក្នុងការងារនិងសង្គម ក្នុងពេលបំពេញការងារជូនធនាគារជាតិនៃកម្ពុជា និងប្រទេសជាតិមាតុភូមិ។

**ប្រការ ៣.-**

ប្រកាសនេះមានវិសាលភាពអនុវត្តចំពោះមន្ត្រីជាន់ខ្ពស់ និងមន្ត្រីក្រមការធនាគារជាតិនៃកម្ពុជានិងអង្គភាពក្រោមឱវាទ សម្រាប់ប្រើប្រាស់នៅពេលចូលរួមពិធីបុណ្យប្រពៃណីជាតិ ពិធីបុណ្យជាតិ និងពិធីផ្លូវការផ្សេងៗ។

## ជំពូកទី ២
## រូបសញ្ញាធនាគារជាតិនៃកម្ពុជា

**ប្រការ ៤.-**

រូបសញ្ញាធនាគារជាតិនៃកម្ពុជាមានសណ្ឋានដូចខាងក្រោម៖

- មានរាងពងក្រពើ
- មានអក្សរ រ:ពោះ «ឆ» ពណ៌ប្រាក់ស្ថិតនៅចំកណ្តាលផ្ទៃពណ៌ស
- នៅព័ទ្ធសងខាងអក្សរ «ឆ» មានកួរស្រូវពណ៌មាស៣(បី)ម្ខាង ចងភ្ជួចនៅបាតខាងក្រោម មានរាងជាផ្កាឈូកដោយលេចចេញនូវគល់ស្រូវខ្វែងគ្នា២(ពីរ) ហើយមានរំលេចដោយគ្រាប់ស្រូវពណ៌មាស៣(បី)គ្រាប់រាយគ្នាជាកង់ៗ ពីក្រោមទៅលើចំនួន៧(ប្រាំពីរ)កង់ ជារាងស្នែងក្របី និងមានចុងស្លឹកម្ខាង៤(បួន)សន្លឹកខិតជិតគ្នា។

រូបសញ្ញាធនាគារជាតិនៃកម្ពុជានេះត្រូវបានប្រើសម្រាប់ដាក់នៅលើស័ក្តិស្មា និងស័ក្តិចុងកអាវ នៃមន្ត្រីក្របខ័ណ្ឌមន្ត្រីជាន់ខ្ពស់និងក្របខ័ណ្ឌមន្ត្រីក្រមការ និងដាក់នៅលើស័ក្តិខ្វាស់លើអាវបុរស ឬលើក្រមាពាក់នារី ដែលជាមន្ត្រីក្របខ័ណ្ឌមន្ត្រីជាន់ខ្ពស់ និងក្របខ័ណ្ឌមន្ត្រីក្រមការ។

រូបសញ្ញាធនាគារជាតិនៃកម្ពុជានេះ មានរូបភាពដូចក្នុងឧបសម្ព័ន្ធទី១នៃប្រកាសនេះ។

## ជំពូកទី ៣
## សញ្ញាស័ក្តិ

### ប្រការ ៥.- សម្រាប់ក្របខ័ណ្ឌមន្ត្រីជាន់ខ្ពស់

សញ្ញាស័ក្តិសម្រាប់មន្ត្រីក្របខ័ណ្ឌមន្ត្រីជាន់ខ្ពស់ ត្រូវបានកំណត់ដូចតទៅ៖

**១- សម្រាប់ឋានន្តរស័ក្តិឧត្តមមន្ត្រី**

**ក- អំពីស័ក្តិស្មា**

ស័ក្តិស្មា មានលក្ខណៈសម្គាល់ដូចតទៅ៖

ក១: មានផ្ទៃពណ៌ខៀវចាស់ និងមានរចនាគុបតែងដោយក្បាច់ភ្ញីវល្លិ៍ពណ៌មាស ១(មួយ)មែក មាន៦(ប្រាំមួយ)សន្លឹក ៥(ប្រាំ)ផ្លែ និងផ្ការីក១(មួយ)ទង។ នៅខាងចុងផ្នែកខាងលើនៃក្បាច់ មានរូបផ្កាឈូកពណ៌មាស១(មួយ)ទង និងមានត្របក ៣(បី)

ក២: លើផ្កាឈូក មានរូបសញ្ញាធនាគារជាតិនៃកម្ពុជា ពណ៌មាស ១(មួយ)

ក៣: លើរូបសញ្ញាធនាគារជាតិនៃកម្ពុជា មានឡេវរូបព្រះរាជសង្ហារនៃព្រះរាជាណាចក្រកម្ពុជាពណ៌មាស១(មួយ)គ្រាប់

ក៤: នៅជុំវិញរូបនៃចំណុច ក១-ក២-ក៣ មានរូបភាពកញ្ចុំគ្រាប់ស្រូវពណ៌មាស ៣(បី)គ្រាប់ដាក់រាយគ្នាជាជួរ ជាលម្អ។ នៅព័ទ្ធជុំវិញកញ្ចុំគ្រាប់ស្រូវនេះ មានឆ្នូតព្ធរវេញពណ៌មាស ៣(បី)ខ្សែនៅតាមជរជាយជុំវិញស័ក្តិ សម្រាប់សម្គាល់ឋានន្តរស័ក្តិឧត្តមមន្ត្រី។

**ខ- អំពីស័ក្តិចុងកអាវ**

ស័ក្តិចុងកអាវ មានលក្ខណៈសម្គាល់ដូចតទៅ៖

ខ១: មានផ្ទៃពណ៌ខៀវចាស់ និងមានរូបសញ្ញាធនាគារជាតិនៃកម្ពុជា ពណ៌មាស១(មួយ) នៅខាងដើម

ខ២: មានរូបភាពក្បាច់ភ្ញីវល្លិ៍ពណ៌មាស១(មួយ)មែក មាន៤(បួន)សន្លឹក ៥(ប្រាំ)ផ្លែ

ខ៣: មានរូបផ្កាឈូកពណ៌មាស១(មួយ)ទង និងមានគ្រាបក៣(បី)ភ្ជាប់ជាមួយក្បាច់ភ្ញីវល្លិ៍

ខ៤: នៅជុំវិញរូបភាពនៃចំណុច ខ១-ខ២-ខ៣ មានរូបភាពកញ្ចុំ គ្រាប់ស្រូវពណ៌មាស៣(បី)គ្រាប់ដាក់រាយគ្នាជាជួរ ជាលម្អជុំវិញ។ នៅផ្នែកខាងមុខ និងខាងលើនៃជួរកញ្ចុំគ្រាប់ស្រូវ មានឆ្នូតពួរវេញ ពណ៌មាស ៣(បី)ខ្សែ សម្រាប់សម្គាល់ឋានន្តរស័ក្តិឧត្តមមន្ត្រី។

## គ- អំពីស័ក្តិចុងដៃអាវ

ស័ក្តិចុងដៃអាវ មានលក្ខណៈសម្គាល់ដូចតទៅ៖

គ១: មានផ្ទៃពណ៌ខៀវចាស់ និងមានរចនាតុបតែងដោយក្បាច់ភ្ញីវល្លិ៍ពណ៌មាស ១(មួយ)មែកយ៉ាងវែង រត់តាមបណ្តោយផ្ទៃស័ក្តិ មាន៩(ប្រាំបួន)ផ្លែ ផ្ការីក ៧(ប្រាំពីរ) មានសន្លឹកក្បាច់ភ្ញីវល្លិ៍ជាច្រើន និងមានរូបផ្កាឈូកពណ៌មាស ១(មួយ)ទង មានគ្រាបក៣(បី) ភ្ជាប់ជាមួយក្បាច់ភ្ញីវល្លិ៍

គ២: នៅផ្នែកខាងមុខនិងខាងលើនៃក្បាច់ភ្ញីវល្លិ៍ មានពួរវេញពណ៌មាស១(មួយ) ឆ្នូត ព័ទ្ធជុំវិញក្បាច់ភ្ញីវល្លិ៍ និងមានរូបភាពកញ្ចុំគ្រាប់ស្រូវពណ៌មាស ៣(បី) គ្រាប់ដាក់រាយគ្នាជាជួរអមពួរវេញ ជាលម្អជុំវិញ

គ៣: នៅចុងខាងក្រោមបង្អស់នៃស័ក្តិ ផ្នែកខាងមុខនិងខាងលើ មានឆ្នូតពួរវេញ ពណ៌មាស ៣(បី)ខ្សែ សម្រាប់សម្គាល់ឋានន្តរស័ក្តិឧត្តមមន្ត្រី។

រូបសញ្ញាស័ក្តិស្មា ស័ក្តិចុងកអាវ ស័ក្តិចុងដៃអាវសម្រាប់មន្ត្រីក្របខ័ណ្ឌមន្ត្រីជាន់ខ្ពស់ ឋានន្តរស័ក្តិឧត្តមមន្ត្រី មានដូចក្នុងឧបសម្ព័ន្ធទី២ នៃប្រកាសនេះ។

## ឃ- អំពីស័ក្តិខ្ទាស់លើអាវ

ស័ក្តិខ្ទាស់លើអាវ មានលក្ខណៈសម្គាល់ដូចតទៅ៖

ឃ១: មានផ្ទៃពណ៌ខៀវចាស់ និងមានរូបសញ្ញាធនាគារជាតិនៃកម្ពុជាពណ៌មាស១(មួយ)។ នៅផ្នែកខាងក្រោមរូបសញ្ញាធនាគារជាតិនៃកម្ពុជានេះ មានសរសេរអក្សរពណ៌មាស "ធនាគារជាតិ នៃ កម្ពុជា"

ឃ២: មានរូបកញ្ចុំគ្រាប់ស្រូវពណ៌មាស៣(បី)គ្រាប់ដាក់រាយគ្នាជាជួរ រាងកោងជាទម្រង់ស្នែងក្របីទ្រូរូបសញ្ញាធនាគារជាតិនៃកម្ពុជា

ឃ៣: នៅផ្នែកខាងក្រោមបង្អស់មានខ្សែពួរវេញពណ៌មាសព័ទ្ធអម ៣(បី)ខ្សែ សម្រាប់សម្គាល់ឋានន្តរស័ក្តិឧត្តមមន្ត្រី។

ស័ក្តិខ្ទាស់លើអាវនេះ ប្រើសម្រាប់ខ្ទាស់លើអាវនៅពេលបំពេញការងារ។ ស័ក្តិនេះ ក៏ត្រូវបានប្រើសម្រាប់ខ្ទាស់លើក្រមាពានានារី ក្នុងឯកសណ្ឋានប្រពៃណីផងដែរ។

រូបគំនូរស័ក្តិខ្ទាស់លើអាវ និងលើក្រមាពានាសម្រាប់មន្ត្រីក្របខ័ណ្ឌមន្ត្រីជាន់ខ្ពស់ ឋានន្តរស័ក្តិឧត្តមមន្ត្រី មានដូចក្នុងឧបសម្ព័ន្ធទី៥ នៃប្រកាសនេះ។

## ២- សម្រាប់ឋានន្តរស័ក្តិវរៈមន្ត្រី

### ក- អំពីស័ក្តិស្មា

ស័ក្តិស្មា មានលក្ខណៈសម្គាល់ដូចតទៅ៖

ក១: មានផ្ទៃពណ៌ខៀវចាស់ និងមានរចនាគុបតែងដោយក្បាច់ភ្ញីវល្លិ៍ពណ៌មាស ១(មួយ)មែក មាន៦(ប្រាំមួយ)សន្លឹក ៥(ប្រាំ)ផ្លែ និងផ្ការីក១(មួយ)ទង។ នៅខាងចុងផ្នែកខាងលើនៃក្បាច់ មានរូបផ្កាឈូកពណ៌មាស១(មួយ)ទង និងមានត្របក៣(បី)

ក២: លើផ្កាឈូក មានរូបសញ្ញាធនាគារជាតិនៃកម្ពុជាពណ៌មាស ១(មួយ)

ក៣: លើរូបសញ្ញាធនាគារជាតិនៃកម្ពុជា មានឡេវរូបព្រះរាជសង្ហារនៃព្រះរាជាណាចក្រកម្ពុជាពណ៌មាស១(មួយ)គ្រាប់

ក៤: នៅជុំវិញរូបនៃចំណុច ក១-ក២-ក៣ មានរូបភាពកញ្ចុំគ្រាប់ស្រូវពណ៌មាស ៣(បី)គ្រាប់ដាក់រាយគ្នាជាជួរ ជាលម្អ។ នៅព័ទ្ធជុំវិញកញ្ចុំគ្រាប់ស្រូវនេះ មានឆ្នូតពួរវេញពណ៌មាស២(ពីរ)ខ្សែនៅតាមជរជាយជុំវិញស័ក្តិ សម្រាប់សម្គាល់ឋានន្តរស័ក្តិវរៈមន្ត្រី។

### ខ- អំពីស័ក្តិចុងកអាវ

ស័ក្តិចុងកអាវ មានលក្ខណៈសម្គាល់ដូចតទៅ៖

ខ១: មានផ្ទៃពណ៌ខៀវចាស់ និងមានរូបសញ្ញាធនាគារជាតិនៃកម្ពុជា ពណ៌មាស១ (មួយ) នៅខាងដើម

ខ២: មានរូបភាពក្បាច់ភ្ញីវល្លិ៍ពណ៌មាស១(មួយ)មែក មាន៤(បួន)សន្លឹក ៥(ប្រាំ)ផ្លែ

ខ៣: មានរូបផ្កាឈូកពណ៌មាស១(មួយ)ទង និងមានត្របក៣(បី)ភ្ជាប់ជាមួយក្បាច់ភ្ញីវល្លិ៍

ខ៤: នៅជុំវិញរូបភាពនៃចំណុច ខ១-ខ២-ខ៣ មានរូបភាពកញ្ចុំគ្រាប់ស្រូវពណ៌មាស៣(បី)គ្រាប់ដាក់រាយគ្នាជាជួរ ជាលម្អជរជាយ។ នៅផ្នែកខាងមុខ និងខាងលើនៃជួរកញ្ចុំគ្រាប់ស្រូវ មានឆ្នូតពួរវេញ ពណ៌មាស ២(ពីរ)ខ្សែ សម្រាប់សម្គាល់ឋានន្តរស័ក្តិវរៈមន្ត្រី។

### គ- អំពីស័ក្តិចុងដៃអាវ

ស័ក្តិចុងដៃអាវ មានលក្ខណៈសម្គាល់ដូចតទៅ៖

គ១: មានផ្ទៃពណ៌ខៀវចាស់ និងមានរចនាគុបតែងដោយក្បាច់ភ្ញីវល្លិ៍ពណ៌មាស១(មួយ)មែកយ៉ាងវែង រត់តាមបណ្ដោយផ្ទៃស័ក្តិ មាន៩(ប្រាំបួន)ផ្លែ ផ្ការីក៧(ប្រាំពីរ) មានសន្លឹកក្បាច់ភ្ញីវល្លិ៍ជាច្រើន និងមានរូបផ្កាឈូកពណ៌មាស១(មួយ)ទង មានត្របក៣(បី) ភ្ជាប់ជាមួយក្បាច់ភ្ញីវល្លិ៍

គ២: នៅផ្នែកខាងមុខនិងខាងលើនៃក្បាច់ភ្ញីវល្លិ៍ មានពូរវេញពណ៌មាស១(មួយ) ឆ្វេតព័ទ្ធជុំវិញក្បាច់ភ្ញីវល្លិ៍ និងមានរូបភាពកញ្ចុំគ្រាប់ស្រូវពណ៌មាស ៣(បី) គ្រាប់ដាក់រាយគ្នាជាជួរអមពូរវេញ ជាលម្អជរជាយ

គ៣: នៅចុងខាងក្រោមបង្អស់នៃស័ក្តិ ផ្នែកខាងមុខនិងខាងលើ មានឆ្វេតពូរវេញពណ៌មាស២(ពីរ)ខ្សែ សម្រាប់សម្គាល់ឋានន្តរស័ក្តិវរៈមន្ត្រី។

រូបសញ្ញាស័ក្តិស្មា ស័ក្តិចុងកអាវ ស័ក្តិចុងដៃអាវសម្រាប់មន្ត្រីក្របខ័ណ្ឌមន្ត្រីជាន់ខ្ពស់ ឋានន្តរស័ក្តិវរៈមន្ត្រី មានដូចក្នុងឧបសម្ព័ន្ធទី៣ នៃប្រកាសនេះ។

**ឃ- អំពីស័ក្តិខ្ទាស់លើអាវ**

ស័ក្តិខ្ទាស់លើអាវ មានលក្ខណៈសម្គាល់ដូចតទៅៈ

ឃ១: មានផ្ទៃពណ៌ខៀវចាស់ និងមានរូបសញ្ញាធនាគារជាតិនៃកម្ពុជាពណ៌មាស ១(មួយ)។ នៅខាងក្រោមរូបសញ្ញាធនាគារជាតិនៃកម្ពុជានេះ មានសរសេរអក្សរពណ៌មាស "ធនាគារជាតិ នៃ កម្ពុជា"

ឃ២: មានរូបកញ្ចុំគ្រាប់ស្រូវពណ៌មាស ៣(បី)គ្រាប់ដាក់រាយគ្នាជាជួររាងកោងជាទម្រង់ស្នែងក្របីទ្រូរូបសញ្ញាធនាគារជាតិនៃកម្ពុជា

ឃ៣: នៅផ្នែកខាងក្រោមបង្អស់មានខ្សែពូរវេញពណ៌មាសព័ទ្ធអម២(ពីរ)ខ្សែ សម្រាប់សម្គាល់ឋានន្តរស័ក្តិវរៈមន្ត្រី។

ស័ក្តិខ្ទាស់លើអាវនេះ ប្រើសម្រាប់ខ្ទាស់លើអាវនៅពេលបំពេញការងារ។ ស័ក្តិនេះ ក៏ត្រូវបានប្រើសម្រាប់ខ្ទាស់លើក្រមាពានានារី ក្នុងឯកសណ្ឋានប្រពៃណីផងដែរ។

រូបគំនូរស័ក្តិខ្ទាស់លើអាវ និងលើក្រមាពានាសម្រាប់មន្ត្រីក្របខ័ណ្ឌមន្ត្រីជាន់ខ្ពស់ ឋានន្តរស័ក្តិវរៈមន្ត្រី មានដូចក្នុងឧបសម្ព័ន្ធទី៥ នៃប្រកាសនេះ។

**៣- សម្រាប់ឋានន្តរស័ក្តិអនុមន្ត្រី**

**ក- អំពីស័ក្តិស្មា**

ស័ក្តិស្មា មានលក្ខណៈសម្គាល់ដូចតទៅៈ

ក១: មានផ្ទៃពណ៌ខៀវចាស់ និងមានរចនាតុបតែងដោយក្បាច់ភ្ញីវល្លិ៍ពណ៌មាស ១(មួយ)មែក មាន៦(ប្រាំមួយ)សន្លឹក ៥(ប្រាំ)ផ្លែ និងផ្ការីក១(មួយ)ទង។ នៅខាងចុងផ្នែកខាងលើនៃក្បាច់ មានរូបផ្កាឈូកពណ៌មាស១(មួយ)ទង និងមានត្របក ៣(បី)

ក២: លើផ្កាឈូក មានរូបសញ្ញាធនាគារជាតិនៃកម្ពុជា ពណ៌មាស ១(មួយ)

ក៣: លើរូបសញ្ញាធនាគារជាតិនៃកម្ពុជា មានឡេរូបព្រះរាជសង្ហារនៃព្រះរាជាណាចក្រកម្ពុជាពណ៌មាស១(មួយ)គ្រាប់

ក៤: នៅជុំវិញរូបនៃចំណុច ក១-ក២-ក៣ មានរូបភាពកញ្ចុំគ្រាប់ស្រូវពណ៌មាស ៣(បី)គ្រាប់ដាក់រាយគ្នាជាជួរ ជាលម្អ។ នៅព័ទ្ធជុំវិញកញ្ចុំគ្រាប់ស្រូវនេះ មានឆ្នូតពួរវេញពណ៌មាស ១(មួយ)ខ្សែនៅតាមជរជាយជុំវិញស័ក្តិ សម្រាប់សម្គាល់ឋានន្តរស័ក្តិអនុមន្ត្រី។

**ខ- អំពីស័ក្តិចុងកអាវ**

ស័ក្តិចុងកអាវ មានលក្ខណៈសម្គាល់ដូចតទៅ៖

ខ១: មានផ្ទៃពណ៌ខៀវចាស់ និងមានរូបសញ្ញាធនាគារជាតិនៃកម្ពុជា ពណ៌មាស១ (មួយ) នៅខាងដើម

ខ២: មានរូបភាពក្បាច់ភ្ញីវល្លិ៍ពណ៌មាស១(មួយ)មែក មាន៤(បួន)សន្លឹក ៥(ប្រាំ)ផ្លែ

ខ៣: មានរូបផ្កាឈូកពណ៌មាស១(មួយ)ទង និងមានត្របក៣(បី)ភ្ជាប់ជាមួយក្បាច់ភ្ញីវល្លិ៍

ខ៤: នៅជុំវិញរូបភាពនៃចំណុច ខ១-ខ២-ខ៣ មានរូបភាពកញ្ចុំគ្រាប់ស្រូវពណ៌មាស៣(បី)គ្រាប់ដាក់រាយគ្នាជាជួរ ជាលម្អជរជាយ។ នៅផ្នែកខាងមុខ និងខាងលើនៃជួរកញ្ចុំគ្រាប់ស្រូវ មានឆ្នូតពួរវេញ ពណ៌មាស ១(មួយ)ខ្សែ សម្រាប់សម្គាល់ឋានន្តរស័ក្តិអនុមន្ត្រី។

**គ- អំពីស័ក្តិចុងដៃអាវ**

ស័ក្តិចុងដៃអាវ មានលក្ខណៈសម្គាល់ដូចតទៅ៖

គ១: មានផ្ទៃពណ៌ខៀវចាស់ និងមានរចនាតុបតែងដោយក្បាច់ភ្ញីវល្លិ៍ពណ៌មាស១(មួយ)មែកយ៉ាងវែង រត់តាមបណ្តោយផ្ទៃស័ក្តិ មាន៩(ប្រាំបួន)ផ្លែ ផ្ការីក៧(ប្រាំពីរ) មានសន្លឹកក្បាច់ភ្ញីវល្លិ៍ជាច្រើន និងមានរូបផ្កាឈូកពណ៌មាស១(មួយ)ទង មានត្របក៣(បី) ភ្ជាប់ជាមួយក្បាច់ភ្ញីវល្លិ៍

គ២: នៅផ្នែកខាងមុខនិងខាងលើនៃក្បាច់ភ្ញីវល្លិ៍ មានពួរវេញពណ៌មាស១(មួយ)ឆ្នូត ព័ទ្ធជុំវិញក្បាច់ភ្ញីវល្លិ៍ និងមានរូបភាពកញ្ចុំគ្រាប់ស្រូវពណ៌មាស ៣(បី)គ្រាប់ដាក់រាយគ្នាជាជួរអមពួរវេញ ជាលម្អជរជាយ

គ៣: នៅចុងខាងក្រោមបង្អស់នៃស័ក្តិ ផ្នែកខាងមុខនិងខាងលើ មានឆ្នូតពួរវេញពណ៌មាស ១(មួយ)ខ្សែ សម្រាប់សម្គាល់ឋានន្តរស័ក្តិអនុមន្ត្រី។

រូបសញ្ញាស័ក្តិស្មា ស័ក្តិចុងកអាវ ស័ក្តិចុងដៃអាវសម្រាប់មន្ត្រីក្របខ័ណ្ឌមន្ត្រីជាន់ខ្ពស់ ឋានន្តរស័ក្តិអនុមន្ត្រី មានដូចក្នុងឧបសម្ព័ន្ធទី៤ នៃប្រកាសនេះ។

**ឃ- អំពីស័ក្តិខ្ចាស់លើអាវ**

ស័ក្តិខ្ចាស់លើអាវ មានលក្ខណៈសម្គាល់ដូចតទៅ៖

ឃ១: មានផ្ទៃពណ៌ខៀវចាស់ និងមានរូបសញ្ញាធនាគារជាតិនៃកម្ពុជាពណ៌មាស១(មួយ)។ នៅខាងក្រោមរូបសញ្ញាធនាគារជាតិនៃកម្ពុជានេះ មានសរសេរអក្សរពណ៌មាស "ធនាគារជាតិ នៃ កម្ពុជា"

ឃ២: មានរូបកញ្ចុំគ្រាប់ស្រូវពណ៌មាស៣(បី)គ្រាប់ដាក់រាយគ្នាជាជួរ រាងកោងជាទម្រង់ស្នែងក្របីទ្រូរូបសញ្ញាធនាគារជាតិនៃកម្ពុជា

ឃ៣: នៅផ្នែកខាងក្រោមបង្អស់មានខ្សែពួរវេញពណ៌មាសព័ទ្ធអម១(មួយ)ខ្សែ សម្រាប់សម្គាល់ឋានន្តរស័ក្តិអនុមន្ត្រី។

ស័ក្តិខ្វាស់លើអាវនេះ ប្រើសម្រាប់ខ្វាស់លើអាវនៅពេលបំពេញការងារ។ ស័ក្តិនេះ ក៏ត្រូវបានប្រើសម្រាប់ខ្វាស់លើក្រមាពាក់នារី ក្នុងឯកសណ្ឋានប្រពៃណីផងដែរ។

រូបគំនូរស័ក្តិខ្វាស់លើអាវ និងលើក្រមាពាក់សម្រាប់មន្ត្រីក្របខ័ណ្ឌមន្ត្រីជាន់ខ្ពស់ឋានន្តរស័ក្តិអនុមន្ត្រី មានដូចក្នុងឧបសម្ព័ន្ធទី៥ នៃប្រកាសនេះ។

## ប្រការ ៦.- សម្រាប់ក្របខ័ណ្ឌមន្ត្រីក្រមការ

សញ្ញាស័ក្តិសម្រាប់មន្ត្រីក្របខ័ណ្ឌមន្ត្រីក្រមការ ត្រូវបានកំណត់ដូចតទៅ៖

### ១- សម្រាប់ឋានន្តរស័ក្តិនាយក្រមការ

#### ក- អំពីស័ក្តិស្មា

ស័ក្តិស្មា មានលក្ខណៈសម្គាល់ដូចតទៅ៖

ក១: មានផ្ទៃពណ៌ខៀវចាស់ និងមានរចនាតុបតែងដោយក្បាច់ភ្ញីវល្លិ៍ពណ៌ប្រាក់ ១(មួយ)មែក មាន៦(ប្រាំមួយ)សន្លឹក ៥(ប្រាំ)ផ្លែ និងផ្ការីក១(មួយ)ទង។ នៅខាងចុងផ្នែកខាងលើនៃក្បាច់ មានរូបផ្កាឈូកពណ៌ប្រាក់១(មួយ)ទង និងមានត្របក៣(បី)

ក២: លើផ្កាឈូក មានរូបសញ្ញាធនាគារជាតិនៃកម្ពុជា ពណ៌ប្រាក់ ១(មួយ)

ក៣: លើរូបសញ្ញាធនាគារជាតិនៃកម្ពុជា មានឡេវរូបព្រះរាជសង្ហារនៃព្រះរាជាណាចក្រកម្ពុជាពណ៌ប្រាក់១(មួយ)គ្រាប់

ក៤: នៅជុំវិញរូបនៃចំណុច ក១-ក២-ក៣ មានរូបភាពកញ្ចុំគ្រាប់ស្រូវពណ៌ប្រាក់ ៣(បី)គ្រាប់ដាក់រាយគ្នាជាជួរ ជាលម្អ។ នៅព័ទ្ធជុំវិញកញ្ចុំគ្រាប់ស្រូវនេះ មានឆ្នូតពួរវេញពណ៌ប្រាក់ ៣(បី)ខ្សែនៅតាមជរជាយជុំវិញស័ក្តិ សម្រាប់សម្គាល់ឋានន្តរស័ក្តិនាយក្រមការ។

#### ខ- អំពីស័ក្តិចុងកអាវ

ស័ក្តិចុងកអាវ មានលក្ខណៈសម្គាល់ដូចតទៅ៖

ខ១: មានផ្ទៃពណ៌ខៀវចាស់ និងមានរូបសញ្ញាធនាគារជាតិនៃកម្ពុជា ពណ៌ប្រាក់១(មួយ) នៅខាងដើម

ខ២: មានរូបភាពក្បាច់ភ្ញីវល្លិ៍ពណ៌ប្រាក់១(មួយ)មែក មាន៤(បួន)សន្លឹក ៥(ប្រាំ)ផ្លែ

ខ៣: មានរូបផ្កាឈូកពណ៌ប្រាក់១(មួយ)ទង និងមានត្របក៣(បី)ភ្ជាប់ជាមួយក្បាច់ភ្ញីវល្លិ៍

ខ៤: នៅជុំវិញរូបភាពនៃចំណុច ខ១-ខ២-ខ៣ មានរូបភាពកញ្ចុំគ្រាប់ស្រូវពណ៌ប្រាក់៣(បី)គ្រាប់ដាក់រាយគ្នាជាជួរ ជាលម្អជរជាយ។ នៅផ្នែកខាងមុខ និងខាងលើនៃជួរកញ្ចុំគ្រាប់ស្រូវ មានឆ្នូតពួរវេញ ពណ៌ប្រាក់ ៣(បី)ខ្សែ សម្រាប់សម្គាល់ឋានន្តរស័ក្តិនាយក្រមការ។

## គ- អំពីស័ក្តិចុងដៃអាវ

ស័ក្តិចុងដៃអាវ មានលក្ខណៈសម្គាល់ដូចតទៅ៖

គ១: មានផ្ទៃពណ៌ខៀវចាស់ និងមានរចនាគុបតែងដោយក្បាច់ភ្ញីល្លើពណ៌ប្រាក់ ១(មួយ)មែកយ៉ាងវែង រត់តាមបណ្តោយផ្ទៃស័ក្តិ មាន៩(ប្រាំបួន)ផ្លែ ផ្ការីក ៧(ប្រាំពីរ) មានសន្លឹកក្បាច់ភ្ញីល្លើជាច្រើន និងមានរូបផ្កាឈូកពណ៌ប្រាក់ ១(មួយ)ទង មានគ្របក៣(បី) ភ្ជាប់ជាមួយក្បាច់ភ្ញីល្លើ

គ២: នៅផ្នែកខាងមុខនិងខាងលើនៃក្បាច់ភ្ញីល្លើ មានពួរវេញពណ៌ប្រាក់១(មួយ) ឆ្នូតព័ទ្ធជុំវិញក្បាច់ភ្ញីល្លើ និងមានរូបភាពកញ្ចុំគ្រាប់ស្រូវពណ៌ប្រាក់ ៣(បី) គ្រាប់ដាក់រាយគ្នាជាជួរអមពួរវេញ ជាលម្អជរជាយ

គ៣: នៅចុងខាងក្រៅបង្អស់នៃស័ក្តិ ផ្នែកខាងមុខនិងខាងលើ មានឆ្នូតពួរវេញ ពណ៌ប្រាក់ ៣(បី)ខ្សែ សម្រាប់សម្គាល់ឋានន្តរស័ក្តិនាយក្រមការ។

រូបសញ្ញាស័ក្តិស្មា ស័ក្តិចុងកអាវ ស័ក្តិចុងដៃអាវសម្រាប់មន្ត្រីក្របខ័ណ្ឌមន្ត្រីក្រមការ ឋានន្តរស័ក្តិនាយក្រមការ មានដូចក្នុងឧបសម្ព័ន្ធទី៦ នៃប្រកាសនេះ។

## ឃ- អំពីស័ក្តិខ្ទាស់លើអាវ

ស័ក្តិខ្ទាស់លើអាវ មានលក្ខណៈសម្គាល់ដូចតទៅ៖

ឃ១: មានផ្ទៃពណ៌ខៀវចាស់ និងមានរូបសញ្ញាធនាគារជាតិនៃកម្ពុជាពណ៌ប្រាក់១(មួយ)។ នៅផ្នែកខាងក្រោមរូបសញ្ញាធនាគារជាតិនៃកម្ពុជានេះ មានសរសេរអក្សរពណ៌ប្រាក់ "ធនាគារជាតិ នៃ កម្ពុជា"

ឃ២: មានរូបកញ្ចុំគ្រាប់ស្រូវពណ៌ប្រាក់៣(បី)គ្រាប់ដាក់រាយគ្នាជាជួរ រាងកោងជាទម្រង់ស្នែងក្របីទ្រូរូបសញ្ញាធនាគារជាតិនៃកម្ពុជា

ឃ៣: នៅផ្នែកខាងក្រោមបង្អស់ មានខ្សែពួរវេញពណ៌ប្រាក់ព័ទ្ធអម៣(បី)ខ្សែ សម្រាប់សម្គាល់ឋានន្តរស័ក្តិនាយក្រមការ។

ស័ក្តិខ្ទាស់លើអាវនេះ ប្រើសម្រាប់ខ្ទាស់លើអាវនៅពេលបំពេញការងារ។ ស័ក្តិនេះ ក៏ត្រូវបានប្រើសម្រាប់ខ្ទាស់លើក្រមាពាក់នានារី ក្នុងឯកសណ្ឋានប្រពៃណីផងដែរ។

រូបគំនូរស័ក្តិខ្ទាស់លើអាវនិងលើក្រមាពាក់សម្រាប់មន្ត្រីក្របខ័ណ្ឌមន្ត្រីក្រមការ ឋានន្តរស័ក្តិនាយក្រមការ មានដូចក្នុងឧបសម្ព័ន្ធទី៩ នៃប្រកាសនេះ។

## ២- សម្រាប់ឋានន្តរស័ក្តិក្រមការដើមខ្សែ

### ក- អំពីស័ក្តិស្មា

ស័ក្តិស្មា មានលក្ខណៈសម្គាល់ដូចតទៅ៖

ក១: មានផ្ទៃពណ៌ខៀវចាស់ និងមានរចនាតុបតែងដោយក្បាច់ភ្ញីរល្ហ័ពណ៌ប្រាក់ ១(មួយ)មែក មាន៦(ប្រាំមួយ)សន្លឹក ៥(ប្រាំ)ផ្លែ និងផ្ការីក១(មួយ)ទង។ នៅខាងចុងផ្នែកខាងលើនៃក្បាច់ មានរូបផ្កាឈូកពណ៌ប្រាក់១(មួយ)ទង និងមានត្របក៣(បី)

ក២: លើផ្កាឈូក មានរូបសញ្ញាធនាគារជាតិនៃកម្ពុជា ពណ៌ប្រាក់ ១(មួយ)

ក៣: លើរូបសញ្ញាធនាគារជាតិនៃកម្ពុជា មានឡេវរូបព្រះរាជសង្ហារនៃព្រះរាជាណាចក្រកម្ពុជាពណ៌ប្រាក់១(មួយ)គ្រាប់

ក៤: នៅជុំវិញរូបនៃចំណុច ក១-ក២-ក៣ មានរូបភាពកញ្ចុំគ្រាប់ស្រូវពណ៌ប្រាក់ ៣(បី)គ្រាប់ដាក់រាយគ្នាជាជួរ ជាលម្អ។ នៅព័ទ្ធជុំវិញកញ្ចុំគ្រាប់ស្រូវនេះ មានឆ្នូតពួរវេញពណ៌ប្រាក់ ២(ពីរ)ខ្សែនៅតាមជរជាយជុំវិញស័ក្តិ សម្រាប់សម្គាល់ឋានន្តរស័ក្តិក្រមការដើមខ្សែ។

### ខ- អំពីស័ក្តិចុងកអាវ

ស័ក្តិចុងកអាវ មានលក្ខណៈសម្គាល់ដូចតទៅ៖

ខ១: មានផ្ទៃពណ៌ខៀវចាស់ និងមានរូបសញ្ញាធនាគារជាតិនៃកម្ពុជា ពណ៌ប្រាក់១(មួយ) នៅខាងដើម

ខ២: មានរូបភាពក្បាច់ភ្ញីរល្ហ័ពណ៌ប្រាក់១(មួយ)មែក មាន៤(បួន)សន្លឹក ៥(ប្រាំ)ផ្លែ

ខ៣: មានរូបផ្កាឈូកពណ៌ប្រាក់១(មួយ)ទង និងមានត្របក៣(បី)ភ្ជាប់ជាមួយក្បាច់ភ្ញីរល្ហ័

ខ៤: នៅជុំវិញរូបភាពនៃចំណុច ខ១-ខ២-ខ៣ មានរូបភាពកញ្ចុំគ្រាប់ស្រូវពណ៌ប្រាក់៣(បី)គ្រាប់ដាក់រាយគ្នាជាជួរ ជាលម្អជរជាយ។ នៅផ្នែកខាងមុខ និងខាងលើនៃជួរកញ្ចុំគ្រាប់ស្រូវ មានឆ្នូតពួរវេញ ពណ៌ប្រាក់ ២(ពីរ)ខ្សែ សម្រាប់សម្គាល់ឋានន្តរស័ក្តិក្រមការដើមខ្សែ។

### គ- អំពីស័ក្តិចុងដៃអាវ

ស័ក្តិចុងដៃអាវ មានលក្ខណៈសម្គាល់ដូចតទៅ៖

គ១: មានផ្ទៃពណ៌ខៀវចាស់ និងមានរចនាតុបតែងដោយក្បាច់ភ្ញីរល្ហ័ពណ៌ប្រាក់១(មួយ)មែកយ៉ាងវែង រត់តាមបណ្តោយផ្ទៃស័ក្តិ មាន៩(ប្រាំបួន)ផ្លែ ផ្ការីក៧(ប្រាំពីរ) មានសន្លឹកក្បាច់ភ្ញីរល្ហ័ជាច្រើន និងមានរូបផ្កាឈូកពណ៌ប្រាក់១(មួយ)ទង មានត្របក៣(បី) ភ្ជាប់ជាមួយក្បាច់ភ្ញីរល្ហ័

គ២: នៅផ្នែកខាងមុខនិងខាងលើនៃក្បាច់ភ្ញីវល្លិ៍ មានពួរវេញពណ៌ប្រាក់១(មួយ) ឆ្លូតព័ទ្ធជុំវិញក្បាច់ភ្ញីវល្លិ៍ និងមានរូបភាពកញ្ចុំគ្រាប់ស្រូវពណ៌ប្រាក់ ៣(បី) គ្រាប់ដាក់វាយគ្នាជាជួរអមពួរវេញ ជាលម្អដរជាយ

គ៣: នៅចុងខាងក្រៅបង្អស់នៃស័ក្តិ ផ្នែកខាងមុខនិងខាងលើ មានឆ្នូតពួរវេញពណ៌ប្រាក់ ២(ពីរ)ខ្សែ សម្រាប់សម្គាល់ឋានន្តរស័ក្តិក្រមការដើមខ្សែ។

រូបសញ្ញាស័ក្តិស្មា ស័ក្តិចុងកអាវ ស័ក្តិចុងដៃអាវសម្រាប់មន្ត្រីក្របខ័ណ្ឌមន្ត្រីក្រមការ ឋានន្តរស័ក្តិក្រមការដើមខ្សែ មានដូចក្នុងឧបសម្ព័ន្ធទី៧ នៃប្រកាសនេះ។

### ឃ- អំពីស័ក្តិខ្ទាស់លើអាវ

ស័ក្តិខ្ទាស់លើអាវ មានលក្ខណៈសម្គាល់ដូចតទៅៈ

ឃ១: មានផ្ទៃពណ៌ខៀវចាស់ និងមានរូបសញ្ញាធនាគារជាតិនៃកម្ពុជាពណ៌ប្រាក់១(មួយ)។ នៅខាងក្រោមរូបសញ្ញាធនាគារជាតិនៃកម្ពុជានេះ មានសរសេរអក្សរពណ៌ប្រាក់ "ធនាគារជាតិ នៃ កម្ពុជា"

ឃ២: មានរូបកញ្ចុំគ្រាប់ស្រូវពណ៌ប្រាក់៣(បី)គ្រាប់ដាក់វាយគ្នាជាជួរ រាងកោងជាទម្រង់ស្នែងក្របីទ្រូរូបសញ្ញាធនាគារជាតិនៃកម្ពុជា

ឃ៣: នៅផ្នែកខាងក្រោមបង្អស់ មានខ្សែពួរវេញពណ៌ប្រាក់ព័ទ្ធអម២(ពីរ)ខ្សែ សម្រាប់សម្គាល់ឋានន្តរស័ក្តិក្រមការដើមខ្សែ។

ស័ក្តិខ្ទាស់លើអាវនេះ ប្រើសម្រាប់ខ្ទាស់លើអាវនៅពេលបំពេញការងារ។ ស័ក្តិនេះ ក៏ត្រូវបានប្រើសម្រាប់ខ្ទាស់លើក្រមាពានានារី ក្នុងឯកសណ្ឋានប្រពៃណីផងដែរ។

រូបគំនូរស័ក្តិខ្ទាស់លើអាវនិងលើក្រមាពានាសម្រាប់មន្ត្រីក្របខ័ណ្ឌមន្ត្រីក្រមការ ឋានន្តរស័ក្តិក្រមការដើមខ្សែ មានដូចក្នុងឧបសម្ព័ន្ធទី៨ នៃប្រកាសនេះ។

## ៣- សម្រាប់ឋានន្តរស័ក្តិក្រមការ

### ក- អំពីស័ក្តិស្មា

ស័ក្តិស្មា មានលក្ខណៈសម្គាល់ដូចតទៅៈ

ក១: មានផ្ទៃពណ៌ខៀវចាស់ និងមានរចនាតុបតែងដោយក្បាច់ភ្ញីវល្លិ៍ពណ៌ប្រាក់ ១(មួយ)មែក មាន៦(ប្រាំមួយ)សន្លឹក ៥(ប្រាំ)ផ្លែ និងផ្ការីក១(មួយ)ទង។ នៅខាងចុងផ្នែកខាងលើនៃក្បាច់ មានរូបផ្កាឈូកពណ៌ប្រាក់១(មួយ)ទង និងមានត្របក៣(បី)

ក២: លើផ្កាឈូក មានរូបសញ្ញាធនាគារជាតិនៃកម្ពុជា ពណ៌ប្រាក់ ១(មួយ)

ក៣: លើរូបសញ្ញាធនាគារជាតិនៃកម្ពុជា មានឡេវរូបព្រះរាជសង្ហារនៃព្រះរាជាណាចក្រកម្ពុជាពណ៌ប្រាក់១(មួយ)គ្រាប់

ក៤: នៅជុំវិញរូបនៃចំណុច ក១-ក២-ក៣ មានរូបភាពកញ្ចុំគ្រាប់ស្រូវពណ៌ប្រាក់ ៣(បី)គ្រាប់ដាក់រាយគ្នាជាជួរ ជាលម្អ។ នៅព័ទ្ធជុំវិញកញ្ចុំគ្រាប់ស្រូវនេះ មានឆ្នូតពួរវេញពណ៌ប្រាក់ ១(មួយ)ខ្សែនៅតាមជរជាយជុំវិញស័ក្តិសម្រាប់សម្គាល់ឋានន្តរស័ក្តិក្រមការ។

**ខ- អំពីស័ក្តិចុងកអាវ**

ស័ក្តិចុងកអាវ មានលក្ខណៈសម្គាល់ដូចតទៅ៖

ខ១: មានផ្ទៃពណ៌ខៀវចាស់ និងមានរូបសញ្ញាធនាគារជាតិនៃកម្ពុជា ពណ៌ប្រាក់១(មួយ) នៅខាងដើម

ខ២: មានរូបភាពក្បាច់ភ្ញីរល្លីពណ៌ប្រាក់១(មួយ)មែក មាន៤(បួន)សន្លឹក ៥(ប្រាំ)ផ្លែ

ខ៣: មានរូបផ្កាឈូកពណ៌ប្រាក់១(មួយ)ទង និងមានគ្របក៣(បី)ភ្ជាប់ជាមួយក្បាច់ភ្ញីរល្លី

ខ៤: នៅជុំវិញរូបភាពនៃចំណុច ខ១-ខ២-ខ៣ មានរូបភាពកញ្ចុំគ្រាប់ស្រូវពណ៌ប្រាក់៣(បី)គ្រាប់ដាក់រាយគ្នាជាជួរ ជាលម្អជរជាយ។ នៅផ្នែកខាងមុខ និងខាងលើនៃជួរកញ្ចុំគ្រាប់ស្រូវ មានឆ្នូតពួរវេញពណ៌ប្រាក់ ១(មួយ)ខ្សែ សម្រាប់សម្គាល់ឋានន្តរស័ក្តិក្រមការ។

**គ- អំពីស័ក្តិចុងដៃអាវ**

ស័ក្តិចុងដៃអាវ មានលក្ខណៈសម្គាល់ដូចតទៅ៖

គ១: មានផ្ទៃពណ៌ខៀវចាស់ និងមានរចនាគុបគែងដោយក្បាច់ភ្ញីរល្លីពណ៌ប្រាក់១(មួយ)មែកយ៉ាងវែង រត់តាមបណ្តោយផ្ទៃស័ក្តិ មាន៩(ប្រាំបួន)ផ្លែ ផ្ការីក៧(ប្រាំពីរ) មានសន្លឹកក្បាច់ភ្ញីរល្លីជាច្រើន និងមានរូបផ្កាឈូកពណ៌ប្រាក់១(មួយ)ទង មានគ្របក៣(បី) ភ្ជាប់ជាមួយក្បាច់ភ្ញីរល្លី

គ២: នៅផ្នែកខាងមុខនិងខាងលើនៃក្បាច់ភ្ញីរល្លី មានពួរវេញពណ៌ប្រាក់១(មួយ) ឆ្នូតព័ទ្ធជុំវិញក្បាច់ភ្ញីរល្លី និងមានកញ្ចុំគ្រាប់ស្រូវពណ៌ប្រាក់ ៣(បី)គ្រាប់ ដាក់រាយគ្នាជាជួរអមពួរវេញ ជាលម្អជរជាយ

គ៣: នៅចុងខាងក្រៅបង្អស់នៃស័ក្តិ ផ្នែកខាងមុខនិងខាងលើ មានឆ្នូតពួរវេញពណ៌ប្រាក់១(មួយ)ខ្សែ សម្រាប់សម្គាល់ឋានន្តរស័ក្តិក្រមការ។

រូបសញ្ញាស័ក្តិស្មា ស័ក្តិចុងកអាវ ស័ក្តិចុងដៃអាវសម្រាប់មន្ត្រីក្របខ័ណ្ឌមន្ត្រីក្រមការ ឋានន្តរស័ក្តិក្រមការ មានដូចក្នុងឧបសម្ព័ន្ធទី៨ នៃប្រកាសនេះ។

**ឃ- អំពីស័ក្តិខ្នាស់លើអាវ**

ស័ក្តិខ្នាស់លើអាវ មានលក្ខណៈសម្គាល់ដូចតទៅ៖

ឃ១: មានផ្ទៃពណ៌ខៀវចាស់ និងមានរូបសញ្ញាធនាគារជាតិនៃកម្ពុជាពណ៌ប្រាក់១(មួយ)។ នៅផ្នែកខាងក្រោមរូបសញ្ញាធនាគារជាតិនៃកម្ពុជានេះ មានសរសេរអក្សរពណ៌ប្រាក់ "ធនាគារជាតិ នៃ កម្ពុជា"

ឃ₂: មានកញ្ចាំគ្រាប់ស្រូវពណ៌ប្រាក់៣(បី)គ្រាប់ដាក់រាយគ្នាជាជួររាងកោងជាទម្រង់ស្មែងក្របីទ្រង់រូបសញ្ញាធនាគារជាតិនៃកម្ពុជា

ឃ₃: នៅផ្នែកខាងក្រោមបង្អស់ មានខ្សែព្ធរវេញពណ៌ប្រាក់ព័ទ្ធអម ១(មួយ) ខ្សែសម្រាប់សម្គាល់ឋានន្តរស័ក្តិក្រមការ។

ស័ក្តិខ្ទាស់លើអាវនេះ ប្រើសម្រាប់ខ្ទាស់លើអាវនៅពេលបំពេញការងារ។ ស័ក្តិនេះ ក៏ត្រូវបានប្រើសម្រាប់ខ្ទាស់លើក្រមាពានានារី ក្នុងឯកសណ្ឋានប្រពៃណីផងដែរ។

រូបគំនូរស័ក្តិខ្ទាស់លើអាវនិងលើក្រមាពានាសម្រាប់មន្ត្រីក្របខ័ណ្ឌមន្ត្រីក្រមការឋានន្តរស័ក្តិក្រមការ មានដូចក្នុងឧបសម្ព័ន្ធទី៩ នៃប្រកាសនេះ។

## ប្រការ ៧.- អំពីខ្ចាតរបស់សញ្ញាស័ក្តិ

ខ្នាតរបស់សញ្ញាស័ក្តិសម្រាប់មន្ត្រីក្របខ័ណ្ឌមន្ត្រីជាន់ខ្ពស់ និងមន្ត្រីក្របខ័ណ្ឌមន្ត្រីក្រមការ ត្រូវបានកំណត់ដូចគ្នា ដូចតទៅ៖

### ១- ខ្នាតស័ក្តិស្មា

ខ្នាតស័ក្តិស្មា ត្រូវបានកំណត់ដូចខាងក្រោម៖

ចំពោះបុរស:

- មានរាងទ្រវែង និងមានចុងស្ទួចរាងត្រីកោណផ្នែកខាងលើ
- មានបណ្ដោយ ប្រវែង ១៣សង្ទីម៉ែត្រ
- មានទទឹងបាតក្រោម ប្រវែង ៦សង្ទីម៉ែត្រ
- មានទទឹងក ប្រវែង ៤,៥០សង្ទីម៉ែត្រ។

ចំពោះនារី:

- មានរាងទ្រវែង និងមានចុងស្ទួចរាងត្រីកោណផ្នែកខាងលើ
- មានបណ្ដោយ ប្រវែង ១២សង្ទីម៉ែត្រ
- មានទទឹងបាតក្រោម ប្រវែង ៥សង្ទីម៉ែត្រ
- មានទទឹងក ប្រវែង ៤សង្ទីម៉ែត្រ។

### ២- ខ្នាតស័ក្តិចុងកអាវ

ខ្នាតស័ក្តិចុងកអាវ ត្រូវបានកំណត់ដូចខាងក្រោម៖

ចំពោះបុរស:

- មានរាងជាចតុកោណព្នាយ
- មានបណ្ដោយ ប្រវែង ៩សង្ទីម៉ែត្រ
- មានទទឹង ប្រវែង ៤សង្ទីម៉ែត្រ។

ចំពោះនារី:

- មានរាងជាចតុកោណព្នាយ
- មានបណ្ដោយ ប្រវែង ៨សង្ទីម៉ែត្រ
- មានទទឹង ប្រវែង ៣,៥០សង្ទីម៉ែត្រ។

**៣- ខ្នាតស័ក្តិចុងដៃអាវ**

ខ្នាតស័ក្តិចុងដៃអាវ ត្រូវបានកំណត់ដូចខាងក្រោម៖

ចំពោះបុរសៈ

- មានរាងបួនជ្រុងទ្រវែង
- មានបណ្តោយ ប្រវែង ៣២សង្ទីម៉ែត្រ
- មានទទឹង ប្រវែង ៩,៧០សង្ទីម៉ែត្រ។

ចំពោះនារីៈ

- មានរាងបួនជ្រុងទ្រវែង
- មានបណ្តោយ ប្រវែង ២៨សង្ទីម៉ែត្រ
- មានទទឹង ប្រវែង ៨សង្ទីម៉ែត្រ ។

**៤- ខ្នាតស័ក្តិខ្នាស់លើអាវ**

ខ្នាតស័ក្តិខ្នាស់លើអាវ ត្រូវបានកំណត់ដូចខាងក្រោម៖

- មានរាងស្លឹកពោធិ៍
- មានកម្ពស់ ប្រវែង ៦,២០សង្ទីម៉ែត្រ
- មានទទឹង ប្រវែង ៥,២០សង្ទីម៉ែត្រ ។

ដោយឡែក ស័ក្តិស្មា ស័ក្តិចុងកអាវ និងស័ក្តិចុងដៃអាវរបស់នារីមានទំហំតូចជាងដូចខាងក្រោម៖

- ចំពោះស័ក្តិស្មា អាចមានទំហំ ៨០% ៨៥% ៩០% នៃទំហំស័ក្តិស្មារបស់បុរស អាស្រ័យលើមាឌរបស់នារី
- ស័ក្តិចុងកអាវ មានទំហំទទឹង ៣ សង្ទីម៉ែត្រ ទៅ៣,៥០ សង្ទីម៉ែត្រ អាស្រ័យលើមាឌរបស់នារី។
- ស័ក្តិចុងដៃអាវ អាចមានទំហំទទឹងស្មើនឹង ៧០% ទៅ ៧៥% នៃទំហំទទឹងស័ក្តិចុងដៃអាវរបស់បុរស អាស្រ័យលើមាឌរបស់នារី។

## ជំពូកទី ៤
## ប្រភេទឯកសណ្ឋាន និងការប្រើប្រាស់

**ប្រការ ៨.-**

ប្រភេទឯកសណ្ឋានសម្រាប់មន្ត្រីក្របខ័ណ្ឌមន្ត្រីជាន់ខ្ពស់ និងក្របខ័ណ្ឌមន្ត្រីក្រមការត្រូវបានកំណត់ដូចខាងក្រោម៖

**១- ឯកសណ្ឋានផ្លូវការ**

**ក- ចំពោះបុរស**

- អាវកុដពណ៌ស កគ្រង់ ដៃវែង កាត់រាងអាវធំ មានបន្ទះលើស្មាសម្រាប់ដាក់ស័ក្តិ និងគ្មានផែកខ្នង។ អាវនេះមានហោប៉ៅចំនួន៤(បួន) គឺហោប៉ៅខាងលើ ២(ពីរ)ដេរបង្កប់ មានគម្របរាងបួនជ្រុងទ្រវែង មានគែមរាងមូល ហោប៉ៅខាងក្រោមពីរដេរបង្កប់ មានគម្របបួនជ្រុងទ្រវែង មានគែមរាងមូល ហើយនៅលើគម្របហោប៉ៅទាំងបួននោះមានឡេវរូបព្រះសង្ហារពណ៌មាស ឬពណ៌ប្រាក់ ទៅតាមប្រភេទក្របខ័ណ្ឌ។ នៅចុងដៃអាវទាំងសងខាង មានឡេវបញ្ឆោតចំនួន៣(បី)រូបព្រះសង្ហារពណ៌មាស ឬពណ៌ប្រាក់ ទៅតាមប្រភេទក្របខ័ណ្ឌ។ អាវកុដពណ៌សនេះ មានឡេវរូបព្រះសង្ហារចំនួន៧(ប្រាំពីរ) ពណ៌មាស ឬពណ៌ប្រាក់ទៅតាមប្រភេទក្របខ័ណ្ឌ
- ខោជើងវែង មានពណ៌ទឹកប៊ិចក្រមៅ ស្បែកជើងឃ្លុបពណ៌ខ្មៅ និងស្រោមជើងពណ៌ខ្មៅ។

**ខ- ចំពោះស្ត្រី**

- អាវជីបរាងពណ៌ស ដោយប្រើសាច់ក្រណាត់ដូចឈុតអាវរបស់បុរស កតាំងគ្មានផែកខ្នង បិទឡេវមុខ ដាក់ឡេវរូបព្រះសង្ហារចំនួន៥(ប្រាំ)ពណ៌មាស ឬពណ៌ប្រាក់ទៅតាមប្រភេទក្របខ័ណ្ឌ។ ចុងកអាវទាំងសងខាងមានស័ក្តិតាមឋានន្តរស័ក្តិ មានបន្ទះលើស្មាសម្រាប់ដាក់ស័ក្តិ គ្មានហោប៉ៅ អាវដៃវែងត្រឹមភ្នែកគោលដៃ ចុងដៃអាវមានស័ក្តិតាមឋានន្តរស័ក្តិ
- សំពត់សំឡយអំពីអន្លូញ មានឆ្នូតពណ៌ខៀវនិងពណ៌ខ្មៅ ដែលឆ្នូតនីមួយៗមានទំហំ១,៥០មីលីម៉ែត្រ មានសម្រុងលើភ្នែកគោលនៃស្មងជើងប្រវែងពី១០ ទៅ ១៥សង្ទីម៉ែត្រ អនុលោមទៅតាមមាឌ និងកម្ពស់
- ស្បែកជើងឃ្លុបមុខ ឃ្លុបក្រោយ មានកែង ពណ៌សសម្រាប់ពេលព្រឹក ឬពណ៌ខ្មៅសម្រាប់ពេលល្ងាច។

រូបគំនូរឯកសណ្ឋានផ្លូវការសម្រាប់បុរស និងស្ត្រី មានគំរូដូចក្នុងឧបសម្ព័ន្ធទី១០ នៃប្រកាសនេះ។

**២- ឯកសណ្ឋានប្រពៃណីជាតិ**

**ក- ចំពោះបុរស**

- អាវកុដពណ៌ស កគ្រង់ ដៃវែង កាត់រាងអាវធំ មានបន្ទះលើស្មាសម្រាប់ដាក់ស័ក្តិនិងគ្មានផែកខ្នង។ អាវនេះ មានហោប៉ៅចំនួន៤(បួន) គឺហោប៉ៅខាងលើ ២(ពីរ)ដេរបង្កប់ មានគម្របរាងបួនជ្រុងទ្រវែង មានគែមរាងមូល ហោប៉ៅខាងក្រោម២(ពីរ)ដេរបង្កប់ មានគម្របរាងបួនជ្រុងទ្រវែង មានគែមរាងមូល ហើយនៅលើគម្របហោប៉ៅទាំងបួននោះ មានឡេវរូបព្រះសង្ហារពណ៌មាស។ នៅចុងដៃអាវទាំងសងខាង មានឡេវបញ្ឆោតចំនួន៣(បី) រូបព្រះសង្ហារពណ៌មាស។ អាវកុដពណ៌សនេះ មានឡេវរូបព្រះសង្ហារចំនួន៧(ប្រាំពីរ) ពណ៌មាស

- សំពត់ជាមួងចងក្បិន ពណ៌តាមថ្ងៃ
- ស្បែកជើងឃ្លុបពណ៌ខ្មៅ កខ្លី ស្រោមជើងពណ៌ខ្មៅដល់ក្បាលជង្គង់។

**ខ- ចំពោះស្ត្រី**

- សំពត់ជាមួងចងក្បិន ពណ៌តាមថ្ងៃ ពាក់ជាមួយអាវពណ៌ស មានកម្ពស ដៃវែង និងមានស័ក្តិនៅចុងដៃអាវ
- ពានាក្រមាតាមពណ៌សំពត់ ឬពានាក្រមាពណ៌ស៊ីទ្រូន [១] តាមពិធីការកំណត់
- នៅលើក្រមាពានាផ្នែកខាងឆ្វេងនៃដើមទ្រូង មានខ្ទាស់សញ្ញាសម្គាល់ឋានន្តរស័ក្តិឧត្តមមន្ត្រី
- ស្បែកជើងឃ្លុបមុខ ឃ្លុបក្រោយ មានកែងពណ៌សសម្រាប់ពេលព្រឹក ឬពណ៌ខ្មៅសម្រាប់ពេលល្ងាច
- កាបូបយួរដៃពណ៌ស ឬពណ៌ខ្មៅ (មិនឱ្យស្ពាយទេ) ស្របតាមការប្រើស្បែកជើងពណ៌ស ឬពណ៌ខ្មៅ។

រូបគំនូរឯកសណ្ឋានប្រពៃណីជាតិសម្រាប់បុរស និងស្ត្រីដែលស្លៀកសំពត់ជាមួងចងក្បិនមានគំរូដូចក្នុងឧបសម្ព័ន្ធទី១១ នៃប្រកាសនេះ។

**ប្រការ ៩.-**

ការប្រើប្រាស់ឯកសណ្ឋានសម្រាប់មន្ត្រីជាន់ខ្ពស់ និងមន្ត្រីក្រមការ ត្រូវបានកំណត់ដូចខាងក្រោម៖

- ឯកសណ្ឋានផ្លូវការសម្រាប់ប្រើប្រាស់ក្នុងឱកាសទិវាបុណ្យជាតិ និងពិធីផ្លូវការផ្សេងៗទៀតរបស់រដ្ឋ។
- ឯកសណ្ឋានប្រពៃណីជាតិសម្រាប់ប្រើប្រាស់ក្នុងទិវាបុណ្យប្រពៃណីជាតិ និងសាសនាដែលប្រារព្ធធ្វើឡើងនៅក្នុងព្រះបរមរាជវាំង ក្នុងវត្តអារាម ឬទីកន្លែងផ្សេងៗត្រូវបានកំណត់ឱ្យប្រើឯកសណ្ឋាននេះ តែមន្ត្រីក្របខ័ណ្ឌមន្ត្រីជាន់ខ្ពស់ដែលមានឋានន្តរស័ក្តិឧត្តមមន្ត្រី។

ឯកសណ្ឋានទាំងពីរប្រភេទខាងលើនេះ ត្រូវស្លៀកពាក់ទៅតាមការកំណត់របស់គណៈកម្មការអចិន្ត្រៃយ៍រៀបចំបុណ្យជាតិ-អន្តរជាតិ។

## ជំពូកទី ៥
## របបកំណត់ឯកសណ្ឋាន និងសញ្ញាស័ក្តិ

**ប្រការ ១០.-**

ការចំណាយសម្រាប់ផលិតស័ក្តិ ជាបន្ទុករបស់ធនាគារជាតិនៃកម្ពុជា។ រីឯការចំណាយសម្រាប់ឯកសណ្ឋានជាសម្លៀកបំពាក់ ស្បែកជើង និងកាបូប ជាបន្ទុករបស់សាមីខ្លួនផ្ទាល់។

(១)ពណ៌ស៊ីទ្រូន: សម្បុរសលាយលឿងបន្តិច សម្បុរសលាយលឿងខ្ចីបំផុត

## ជំពូកទី ៦
## អវសានប្បញ្ញត្តិ

**ប្រការ ១១.-**

អគ្គលេខាធិការ អគ្គនាយកបច្ចេកទេស អគ្គនាយកត្រួតពិនិត្យ អគ្គបេឡា អគ្គពិនិត្យ ប្រធាននាយកដ្ឋាន អង្គភាពក្រោមឱវាទធនាគារជាតិនៃកម្ពុជា និងមន្ត្រីក្របខ័ណ្ឌមន្ត្រីជាន់ខ្ពស់និងក្របខ័ណ្ឌមន្ត្រីក្រមការធនាគារជាតិនៃកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី១៦ ខែកញ្ញា ឆ្នាំ២០១៤

**ទេសាភិបាល**

ជា.ចាន់តូ

កន្លែងទទួល
- ដូចប្រការ ១១
- សមាជិកក្រុមប្រឹក្សាភិបាលធនាគារជាតិនៃកម្ពុជា
- ទីស្តីការគណៈរដ្ឋមន្ត្រី
  "ដើម្បីជូនជ្រាបជាព័ត៌មាន"
- នាយកដ្ឋានរដ្ឋបាលនៃទីស្តីការគណៈរដ្ឋមន្ត្រី
  "ដើម្បីចុះផ្សាយក្នុងរាជកិច្ច"
- ឯកសារ-កាលប្បវត្តិ

ឧបសម្ព័ន្ធទី១ នៃប្រកាសលេខ ធ៨.០១៤.២៣១ ប្រក. ចុះថ្ងៃទី១២ ខែកញ្ញា ឆ្នាំ២០១៤
ស្តីពីរូបសញ្ញា សញ្ញាស័ក្តិ និងឯកសណ្ឋានមន្ត្រីក្របខ័ណ្ឌមន្ត្រីជាន់ខ្ពស់ និងក្របខ័ណ្ឌមន្ត្រីក្រមការធនាគារជាតិនៃកម្ពុជា

## រូបសញ្ញា ធនាគារជាតិនៃកម្ពុជា



ឧបសម្ព័ន្ធទី២ នៃប្រកាសលេខ...ធ៨.០១៤.២៣១ ប្រក ចុះថ្ងៃទី១២ ខែកញ្ញា ឆ្នាំ២០១៤
ស្តីពីរូបសញ្ញា សញ្ញាស័ក្តិ និងឯកសណ្ឋានមន្ត្រីក្របខ័ណ្ឌមន្ត្រីជាន់ខ្ពស់ និងក្របខ័ណ្ឌមន្ត្រីក្រមការធនាគារជាតិនៃកម្ពុជា

# សញ្ញាស័ក្តិមន្ត្រីធនាគារជាតិនៃកម្ពុជាសម្រាប់ឋានន្តរស័ក្តិ ឧត្តមមន្ត្រី (ពណ៌មាស)



ស័ក្តិស្មា



ស័ក្តិកអាវ



ស័ក្តិចុងដៃអាវ

ឧបសម្ព័ន្ធទី៣ នៃប្រកាសលេខ...ធ៨.០១៤.២៣១ ប្រក ចុះថ្ងៃទី១២ ខែកញ្ញា ឆ្នាំ២០១៤
ស្តីពីរូបសញ្ញា សញ្ញាស័ក្តិ និងឯកសណ្ឋានមន្ត្រីក្របខ័ណ្ឌមន្ត្រីជាន់ខ្ពស់ និងក្របខ័ណ្ឌ
មន្ត្រីក្រមការធនាគារជាតិនៃកម្ពុជា

# សញ្ញាស័ក្តិមន្ត្រីធនាគារជាតិនៃកម្ពុជាសម្រាប់ឋានន្តរស័ក្តិ ឋរៈមន្ត្រី (ពណ៌មាស)



ស័ក្តិស្មា



ស័ក្តិករអាវ



ស័ក្តិចុងដៃអាវ

ឧបសម្ព័ន្ធទី៤ នៃប្រកាសលេខ...ធ៨.០១៤.២៣១ ប្រក ចុះថ្ងៃទី១២ ខែកញ្ញា ឆ្នាំ២០១៤
ស្តីពីរូបសញ្ញា សញ្ញាស័ក្តិ និងឯកសណ្ឋានមន្ត្រីក្របខ័ណ្ឌមន្ត្រីជាន់ខ្ពស់ និងក្របខ័ណ្ឌមន្ត្រីក្រមការធនាគារជាតិនៃកម្ពុជា

## សញ្ញាស័ក្តិមន្ត្រីធនាគារជាតិនៃកម្ពុជាសម្រាប់ឋានន្តរស័ក្តិ អនុមន្ត្រី (ពណ៌មាស)



ស័ក្តិស្មា



ស័ក្តិកអាវ



ស័ក្តិចុងដៃអាវ

ឧបសម្ព័ន្ធទី៥ នៃប្រកាសលេខ ធ៨.០១៤.២៣១ ប្រក ចុះថ្ងៃទី១២ ខែកញ្ញា ឆ្នាំ២០១៤
ស្តីពីរូបសញ្ញា សញ្ញាស័ក្តិ និងឯកសណ្ឋានមន្ត្រីក្របខ័ណ្ឌមន្ត្រីជាន់ខ្ពស់ និងក្របខ័ណ្ឌមន្ត្រីក្រមការធនាគារជាតិនៃកម្ពុជា

## ស័ក្តិខ្ចាស់លើដើមទ្រូង សម្រាប់មន្ត្រីជាន់ខ្ពស់ធនាគារជាតិនៃកម្ពុជា (ពណ៌មាស)



ស័ក្តិខ្ចាស់លើអាវ
ឋានន្តរស័ក្តិឧត្តមមន្ត្រី



ស័ក្តិខ្ចាស់លើអាវ
ឋានន្តរស័ក្តិវរៈមន្ត្រី



ស័ក្តិខ្ចាស់លើអាវ
ឋានន្តរស័ក្តិអនុមន្ត្រី

ឧបសម្ព័ន្ធទី៦ នៃប្រកាសលេខ...ធ៨.០១៤.២៣១ ប្រក ចុះថ្ងៃទី១២ ខែកញ្ញា ឆ្នាំ២០១៤
ស្តីពីរូបសញ្ញា សញ្ញាស័ក្តិ និងឯកសណ្ឋានមន្ត្រីក្របខ័ណ្ឌមន្ត្រីជាន់ខ្ពស់ និងក្របខ័ណ្ឌមន្ត្រីក្រមការធនាគារជាតិនៃកម្ពុជា

## សញ្ញាស័ក្តិមន្ត្រីធនាគារជាតិនៃកម្ពុជាសម្រាប់ឋានន្តរស័ក្តិ នាយក្រមការ (ពណ៌ប្រាក់)



ស័ក្តិស្មា



ស័ក្តិករអាវ



ស័ក្តិចុងដៃអាវ

ឧបសម្ព័ន្ធទី៧ នៃប្រកាសលេខ...ធ៨.០១៤.២៣១ ប្រក ចុះថ្ងៃទី១២ ខែកញ្ញា ឆ្នាំ២០១៤
ស្តីពីរូបសញ្ញា សញ្ញាស័ក្តិ និងឯកសណ្ឋានមន្ត្រីក្របខ័ណ្ឌមន្ត្រីជាន់ខ្ពស់ និងក្របខ័ណ្ឌមន្ត្រីក្រមការធនាគារជាតិនៃកម្ពុជា

## សញ្ញាស័ក្តិមន្ត្រីធនាគារជាតិនៃកម្ពុជាសម្រាប់ឋានន្តរស័ក្តិ ក្រមការដើមខ្សែ (ពណ៌ប្រាក់)



ស័ក្តិស្មា



ស័ក្តិករអាវ



ស័ក្តិចុងដៃអាវ

ឧបសម្ព័ន្ធទី៨ នៃប្រកាសលេខ ធ៨.០១៤.២៣១ ប្រក ចុះថ្ងៃទី១២ ខែកញ្ញា ឆ្នាំ២០១៤ ស្តីពីរូបសញ្ញា សញ្ញាស័ក្តិ និងឯកសណ្ឋានមន្ត្រីក្របខ័ណ្ឌមន្ត្រីជាន់ខ្ពស់ និងក្របខ័ណ្ឌមន្ត្រីក្រមការធនាគារជាតិនៃកម្ពុជា

# សញ្ញាស័ក្តិមន្ត្រីធនាគារជាតិនៃកម្ពុជាសម្រាប់ឋានន្តរស័ក្តិ ក្រមការ (ពណ៌ប្រាក់)



ស័ក្តិស្មា



ស័ក្តិករអាវ



ស័ក្តិចុងដៃអាវ

ឧបសម្ព័ន្ធទី៩ នៃប្រកាសលេខ ធ៨.០១៤.២៣១ ប្រក ចុះថ្ងៃទី១២ ខែកញ្ញា ឆ្នាំ២០១៤
ស្តីពីរូបសញ្ញា សញ្ញាស័ក្តិ និងឯកសណ្ឋានមន្ត្រីក្របខ័ណ្ឌមន្ត្រីជាន់ខ្ពស់ និងក្របខ័ណ្ឌមន្ត្រីក្រមការធនាគារជាតិនៃកម្ពុជា

## ស័ក្តិខ្ចាស់លើដើមទ្រូង សម្រាប់មន្ត្រីក្រមការធនាគារជាតិនៃកម្ពុជា (ពណ៌ប្រាក់)



ស័ក្តិខ្ចាស់លើអាវ
ឋានន្តរស័ក្តិនាយក្រមការ



ស័ក្តិខ្ចាស់លើអាវ
ឋានន្តរស័ក្តិក្រមការដើមខ្សែ



ស័ក្តិខ្ចាស់លើអាវ
ឋានន្តរស័ក្តិក្រមការ

ឧបសម្ព័ន្ធទី១០ នៃប្រកាសលេខ.ធ៨.០១៤.២៣១ ប្រក.ចុះថ្ងៃទី១២ ខែកញ្ញា ឆ្នាំ២០១៤
ស្តីពីរូបសញ្ញា សញ្ញាស័ក្តិ និងឯកសណ្ឋានមន្ត្រីក្របខ័ណ្ឌមន្ត្រីជាន់ខ្ពស់ និងក្របខ័ណ្ឌមន្ត្រីក្រមការធនាគារជាតិនៃកម្ពុជា

## ឯកសណ្ឋានផ្លូវការ សម្រាប់មន្ត្រីធនាគារជាតិនៃកម្ពុជា



ស្ត្រី



បុរស

ឧបសម្ព័ន្ធទី១១ នៃប្រកាសលេខ ធ៧.០១៤.២៣១ ប្រក ចុះថ្ងៃទី១២ ខែកញ្ញា ឆ្នាំ២០១៤ ស្តីពីរូបសញ្ញា សញ្ញាស័ក្តិ និងឯកសណ្ឋានមន្ត្រីក្របខ័ណ្ឌមន្ត្រីជាន់ខ្ពស់ និងក្របខ័ណ្ឌមន្ត្រីក្រមការធនាគារជាតិនៃកម្ពុជា

## ឯកសណ្ឋានប្រពៃណី សម្រាប់មន្ត្រីធនាគារជាតិនៃកម្ពុជា



ស្ត្រី



បុរស